**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទូរគមនាគមន៍កម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ:០០៤....ទ....គ.ល

# សេចក្តីជូនដំណឹងលើកទី២

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃ សេវាទ្រទ្រង់ឧបករណ៍ទូរគមនាគមន៍

## (Technical Support Switching NEAX61E) សំរាប់ឆ្នាំ២០១៨-២០១៩

ទូរគមនាគមន៍កម្ពុជា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា: ទូរគមនាគមន៍កម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈលើកទី២ ដើម្បី ផ្តល់សេវាទ្រទ្រង់ឧបករណ៍ទូរគមនាគមន៍(Technical Support Switching NEAX61E) សំរាប់ឆ្នាំ២០១៨-២០១៩ ។

ទូរគមនាគមន៍កម្ពុជា បានរៀបចំឯកសារសំរាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃទូរគមនាគមន៍កម្ពុជា ដែលមានអាសយដ្ឋាន: ទូរគមនាគមន៍កម្ពុជាអគារលេខ៩៥-៩៧ ផ្លូវព្រះសីហនុ កែងនឹងផ្លូវលេខ១០៥ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៦:៣០នាទីរសៀល ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៦:៣០នាទីរសៀល ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មនៃទូរគមនាគមន៍កម្ពុជា ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃចន្ទ ៦ រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

Telecom Cambodia T.C.

**សន-ទី**

សូមទាក់ទងលេខទូរស័ព្ទលេខ

០២៣ ៧២ ៦៦ ៦៨

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ